## **អភ័យឯកសិទ្ធិ (Immunity)**

តាមច្បាប់អន្តរជាតិ មន្ត្រីរបស់រដ្ឋទទួលបាន អភ័យឯកសិទ្ធិជាច្រើនប្រភេទ រួចពីយុត្តាធិការបរទេស។ អភ័យឯកសិទ្ធិមានពីរប្រភេទ៖ អភ័យឯកសិទ្ធិផ្ទាល់ខ្លួន (personal immunity) និងអភ័យឯកសិទ្ធិតួនាទី (functional immunity)។ ខាងក្រោយនេះ ផ្តល់ជូនចំពោះសកម្មភាព បំពេញជូនរដ្ឋក្នុងតួនាទីរបស់ខ្លួន ជាសកម្មភាពរបស់រដ្ឋ (act of state)។ រីឯ personal immunity ផ្តល់ជូនប្រភេទមន្ត្រីជាក់លាក់ ដូចជាភ្នាក់ងារទូត ប្រមុខរដ្ឋាភិបាល ជាដើម។ ជាទូទៅ អភ័យឯកសិទ្ធិនេះ មានលក្ខណៈដាច់ខាត ពីការចោទប្រកាន់ព្រហ្មទណ្ឌ ប្រគល់ជូនក្នុងអំឡុងពេលមន្ត្រីកាន់តួនាទី។

បច្ចុប្បន្ននេះ អភ័យឯកសិទ្ធិទាំងពីរនេះ មិនអាចរួចផុតពីការចោទប្រកាន់បទឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ដូចជាប្រល័យពូជសាសន៍ (genocide) ទេ។ នេះដោយសារ៖ ទី១. សកម្មភាពរបស់រដ្ឋ មិនអាចជាការប្រព្រឹត្តបទឧក្រិដ្ឋកម្មអន្តរជាតិទេ។ ទី២. បុគ្គលមិនអាចសំអាងរួចពីចោទប្រកាន់បទឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិបានឡើយ។ ការបដិសេធនេះ មានតាំងពីក្នុងលក្ខន្តិកៈ Nuremburg (លក្ខន្តិកៈមាត្រា៧)។ ទោះបីជាយ៉ាងនេះក្តី តាមយុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិ (international court of justice) ក្នុងអំឡុង ពេលស្ថិតនៅក្នុងតំណែង បុគ្គលនៅតែមានអភ័យឯកសិទ្ធិដាច់ខាត (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 367-368)។

**ខ្លឹមសារបន្ថែម៖** ទោះបីជាមានទិន្នាការ មិនផ្តល់ជូនទូវអភ័យឯកសិទ្ធិរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ក៏ប៉ុន្តែ អាជ្ញាធររដ្ឋនៅតែមានអភ័យឯកសិទ្ធិពីការទទួលខុសត្រូវរដ្ឋប្បវេណី (immunity from civil litigation)។